# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៩១ សសរ

## សេចក្ដីសម្រេច
## ស្ដីពី
## ការកែសម្រួលសមាសភាពគណៈកម្មការជំនាញដើម្បីគ្រប់គ្រងបន្ត លើនាវាបរទេសដែលទទួលបានការចុះបញ្ជីជាតទង់ជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- ឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្ដីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញសេចក្ដីសម្រេចលេខ ៦៤ សសរ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលស្ដីពីការបញ្ចប់កិច្ចសន្យារវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន COSMOS GROUP
- បានឃើញសេចក្ដីសម្រេចលេខ ៦៥ សសរ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលស្ដីពីការប្រគល់ភារកិច្ចជូនក្រសួងសាធារណការ និងដឹកជញ្ជូន ឲ្យបន្តការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

ប្រការ១៖

ត្រូវបានបង្កើតគណៈកម្មការជំនាញ ដើម្បីគ្រប់គ្រងបន្តលើនាវាបរទេស ដែលទទួលបានការចុះបញ្ជីជាតទង់ជាតិកម្ពុជាហូតដល់បញ្ចប់សុពលភាពនៃវិញ្ញាបនបត្រ ព្រមទាំងទទួលដោះស្រាយនូវរាល់បញ្ហាទាំងឡាយ ដែលអាចកើតមានជាយថាហេតុបន្ទាប់ពីការបញ្ចប់កិច្ចសន្យា ដែលមានសមាសភាព ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម **ស៊ុនចាន់ថុល** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២-ឯកឧត្តម **ឡុច ចាន់កុសល** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន អចិន្ត្រៃយ៍ |
| ៣-ឯកឧត្តម **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |

៤- ឯកឧត្តម **ទី តាឃី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន

៥- ឯកឧត្តម **គឹមរ៉េត សំរេច** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៦- ឯកឧត្តមនាយឧត្តមសេនីយ៍ **ផាន ពៅ** ប្រធានក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ សមាជិក

ប្រការ ២ ៖

គណៈកម្មការជំនាញដើម្បីគ្រប់គ្រងបន្តលើនាវាបរទេស ដែលទទួលបានការចុះបញ្ជីដោតទង់ជាតិកម្ពុជាហូត ដល់បញ្ចប់សុពលភាពនៃវិញ្ញាបនបត្រ ព្រមទាំងទទួលដោះស្រាយនូវរាល់បញ្ហាទាំងឡាយ ដែលអាចកើតមានជាយថាហេតុបន្ទាប់ពីការបញ្ចប់កិច្ចសន្យាមានភារកិច្ចដូចខាងក្រោម៖

-គ្រប់គ្រងបន្ត ចំនួននាវាបរទេសដែលដោតទង់ជាតិកម្ពុជា និងដោះស្រាយបញ្ចប់

-ត្រួតពិនិត្យ និងវាយតម្លៃលើសកម្មភាពនាវា ដែលកំពុងធ្វើនាវាចរណ៍លើផ្ទៃសមុទ្រ

-តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តអនុសញ្ញា កិច្ចព្រមព្រៀង ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវសមុទ្រ

-រៀបចំប្រមូលចងក្រង និងរក្សាទុកនូវឯកសារ ព័ត៌មានជាលាយលក្ខណ៍អក្សរផ្សេងៗពាក់ព័ន្ធនឹងដំណើរការសកម្មភាពរបស់គណៈកម្មការ

-ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

ប្រការ ៣៖

អនុប្រធាន និងសមាជិក នៃគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានមានធុរៈប្រធានអាចប្រគល់ភារកិច្ចជូនអនុប្រធាន ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

ប្រធានគណៈកម្មការអាចអញ្ជើញតំណាងក្រសួង ស្ថាប័ន ផ្នែកឯកជន ឬអ្នកពាក់ព័ន្ធផ្សេងៗទៀតដើម្បីពិគ្រោះយោបល់អំពីការងារជាក់លាក់ណាមួយដែលពាក់ព័ន្ធនឹងការងារគ្រប់គ្រងការចុះបញ្ជីនាវាបរទេសដោតទង់ជាតិកម្ពុជា។

គណៈកម្មការមានសិទ្ធិប្រើត្រារបស់ក្រសួងសាធារណការ និងដឹកជញ្ជូន សម្រាប់ដំណើរការការងាររបស់ខ្លួន។

ប្រការ ៤៖

គណៈកម្មការជំនាញ ដើម្បីគ្រប់គ្រងបន្តលើនាវាបរទេស ដែលទទួលបានការចុះបញ្ជីដោតទង់ជាតិកម្ពុជាមានលេខាធិការដ្ឋានមួយ ជាសេនាធិការ នៅក្រសួងសាធារណការ និងដឹកជញ្ជូន។

លេខាធិការដ្ឋានរបស់គណៈកម្មការជំនាញ ដើម្បីគ្រប់គ្រងបន្តលើនាវាបរទេស ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន តាមការចាំបាច់។

ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាននេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

ប្រការ ៥៖

ការចំណាយសម្រាប់ដំណើរការរបស់គណៈកម្មការជំនាញដើម្បីគ្រប់គ្រងបន្តលើនាវាបរទេស ដែលទទួលការចុះបញ្ជីដោយទង់ជាតិកម្ពុជា ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិ ក្នុងគម្រោងថវិការបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន។

គណៈកម្មការជំនាញដើម្បីគ្រប់គ្រងបន្តលើនាវាបរទេសដែលទទួលការចុះបញ្ជីដោតទង់ជាតិកម្ពុជា មានសិទ្ធិទទួល ចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀត សម្រាប់ដំណើរការ ការងាររបស់ខ្លួន។

ប្រការ ៦៖

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

ប្រការ ៧៖

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ